**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៩៨ កយ.គគស/២០

ថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០២០

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១.-**

បង្កើត **គណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត** ដែលសរសេរជាអក្សរកាត់ថា **គ.យ.ក.ស.** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- លោកជំទាវ **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការប្រចាំការក្រសួងយុត្តិធម៌ | អនុប្រធាន KR |



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

៣- ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន
៤- ឯកឧត្តម **គឹម សន្តិភាព** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
៥- ឯកឧត្តម **ជីវ សុខហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
៦- ឯកឧត្តម **ឡុង នរិន្ទ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
៧- ឯកឧត្តម **ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
៨- ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក និងជាប្រធានលេខាធិការដ្ឋាន។

**គ.យ.ក.ស.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលការងាររួមលើការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
- ដាក់ចេញនូវគោលការណ៍ណែនាំ វិធានការនានា និងផែនការសកម្មភាពចាំបាច់ដើម្បីអនុវត្តយុទ្ធនាការឱ្យមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់សមត្ថភាពស្ថាប័ន ក្នុងការបម្រើសេវាយុត្តិធម៌ឱ្យបានល្អប្រសើរ ក៏ដូចជារួមចំណែកកាត់បន្ថយភាពចង្អៀតណែននៅពន្ធនាគារ
- ដាក់ចេញនូវដំណោះស្រាយបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តយុទ្ធនាការ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធនាការ។

**គ.យ.ក.ស.** ត្រូវដំណើរការកិច្ចប្រជុំរបស់ខ្លួនតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន។ ប្រធាន **គ.យ.ក.ស.** អាចប្រគល់សិទ្ធិជូនអនុប្រធាន ក្នុងការដឹកនាំកិច្ចប្រជុំក្នុងករណីចាំបាច់។ **គ.យ.ក.ស.** ប្រើប្រាស់ត្រា និងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន។

**គ.យ.ក.ស.** មានក្រុមការងារចំនួនបួនជាសេនាធិការដឹកនាំការអនុវត្តយុទ្ធនាការនៅតាមសាលាដំបូង និងមានលេខាធិការដ្ឋានមួយជាសេនាធិការគាំទ្រផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

**ប្រការ២**.-

ក្រុមការងារទាំង ០៤ (បួន) ដែលជាសេនាធិការដឹកនាំការអនុវត្តយុទ្ធនាការរបស់ **គ.យ.ក.ស.** មានការបែងចែកតំបន់ទទួលខុសត្រូវនៅតាមសាលាដំបូង និងមានសមាសភាពដូចខាងក្រោម៖

**ក/ ក្រុមការងារទីមួយ ៖** ទទួលបន្ទុកការអនុវត្តយុទ្ធនាការនៅសាលាដំបូង **រាជធានីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង និងខេត្តស្វាយរៀង** ដែលមានសមាសភាព៖

១- ឯកឧត្តម **គឹម សន្តិភាព** រដ្ឋលេខាធិការ ប្រធាន
២- ឯកឧត្តម **អ៊ូ វ៉ាស៊ី** អនុរដ្ឋលេខាធិការ អនុប្រធាន
៣- ឯកឧត្តម **ម៉ែន ពេជ្រសាលី** អគ្គនាយក អនុប្រធាន
៤- លោកជំទាវ **សួរ ដានី** អគ្គលេខាធិការរង សមាជិក
៥- លោក **លាវ ពិសិដ្ឋ** អគ្គលេខាធិការរង សមាជិក
៦- ឯកឧត្តម **សុច សុផាន់ណារ៉ា** អគ្គនាយករង សមាជិក KR

| | | |
|---|---|---|
| ៧- ឯកឧត្តម **ច័ន្ទ សន្ថា** | អគ្គនាយករង | សមាជិក |
| ៨- លោក **នាង ស៊ីណាវឌ្ឍនៈ** | អគ្គនាយករង | សមាជិក |
| ៩- លោកស្រី **ស៊ុន សុខាលីដា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១០- លោក **ម៉ែន ចំណាន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១១- លោកស្រី **សារឿន សុពណ៌** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២- លោក **ឃី ឈិត** | អធិការ | សមាជិក |
| ១៣- លោក **អ៊ីង រី** | ព្រះរាជអាជ្ញារង | សមាជិក |
| ១៤- លោក **ឈឹម សារ៉ែន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥- លោក **ចាន់ ចិន្តា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦- លោក **ហ៊ីង ចាន់ថុល** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៧- លោកស្រី **រាម នាវតី** | ប្រធានការិយាល័យ | សមាជិក |
| ១៨- លោក **ឌី មថិលា** | ប្រធានការិយាល័យ | សមាជិក |
| ១៩- លោក **ឃាក វិសាលរតនៈ** | ប្រធានការិយាល័យ | សមាជិក |
| ២០- លោក **ស៊ឹម មករា** | អនុប្រធានការិយាល័យ | សមាជិក |
| ២១- លោក **ជា សុខរ័ត្ន** | អនុប្រធានការិយាល័យ | សមាជិក |
| ២២- លោក **ធូ ស៊ីទួន** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | សមាជិក។ |

ខ/ **ក្រុមការងារទីពីរ** ៖ ទទួលបន្ទុកការអនុវត្តយុទ្ធនាការនៅសាលាដំបូង **ខេត្តកំពង់ធំ កំពង់ចាម រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ត្បូងឃ្មុំ និងខេត្តព្រះវិហារ** ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឡុង នរិន្ទ** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **មាស សារឿន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **ខាន់ វណ្ណៈ** | អគ្គាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម **ឡុច សុខលៀង** | អគ្គាធិការរង | សមាជិក |
| ៥- លោក **សៀ តុង** | អគ្គាធិការរង | សមាជិក |
| ៦- លោក **លិន សីលា** | អធិការ | សមាជិក |
| ៧- លោក **ហេង សេង** | អធិការ | សមាជិក |
| ៨- លោក **ស៊ុន ស៊ី** | អធិការ | សមាជិក |
| ៩- លោក **ហួន វណ្ណាហាន** | ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១០- លោកស្រី **សរ ច័ន្ទរ៉ាត** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១១- លោក **ពៅ វិបុល** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២- កញ្ញា **វ៉ាន់ យ៉ានីន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣- លោក **ជា ពេជ្រ** | ព្រះរាជអាជ្ញា | សមាជិក |
| ១៤- លោក **បៀត ច័ន្ទសុភា** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១៥- លោក **កែវ ឧត្តម** | អនុប្រធាននាយកដ្ឋាន | សមាជិក។ KR |

គ/ **ក្រុមការងារទីបី ៖** ទទួលបន្ទុកការអនុវត្តយុទ្ធនាការនៅសាលាដំបូង **ខេត្តកំពង់ឆ្នាំង បន្ទាយមានជ័យ សៀមរាប ប៉ៃលិន បាត់ដំបង ឧត្តរមានជ័យ និងខេត្តពោធិ៍សាត់** ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ជីវ សុខហាក់** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **សួរ ចាន់ធី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **តាន់ហ៊ាង ជាវ័ណ្ណា** | អគ្គនាយក | អនុប្រធាន |
| ៤- ឯកឧត្តម **សៀង គង់** | អគ្គនាយករង | សមាជិក |
| ៥- ឯកឧត្តម **ស៊ឹង ស៊ាំរ៉ាត** | អគ្គលេខាធិការរង | សមាជិក |
| ៦- លោក **នុប សុធនវិសុទ្ធ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៧- លោក **ម៉េង គួង** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៨- លោក **សៀង ហ៊ី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៩- លោកស្រី **និល ហ៊ីលីប** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១០- លោក **លឹម ទីតារ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១១- លោកស្រី **ស្វាន់ វ៉ាន់ធីតា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២- លោក **ឈុន សីហា** | ប្រធានការិយាល័យ | សមាជិក |
| ១៣- លោកស្រី **ហឿន វណ្ណាស័ន** | ប្រធានការិយាល័យ | សមាជិក។ |

ឃ/ **ក្រុមការងារទីបួន ៖** ទទួលបន្ទុកការអនុវត្តយុទ្ធនាការនៅសាលាដំបូង **ខេត្តកំពង់ស្ពឺ តាកែវ ព្រះសីហនុ កំពត និងខេត្តកោះកុង** ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ជិន ម៉ាលីន** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **ឃ្លោក ដារ៉ា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៣- លោក **សុខ មូរ៉ា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៤- លោក **កេត ស៊ីណែត** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក **ឃីម តុខខួច** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោក **ញឹម សុធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧- កញ្ញា **ហេង ស៊ីណែត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨- លោក **ឡុំ សាឡុង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៩- លោក **ជួន ចំរើន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១០- លោក **កៅ សុខហេង** | ប្រធានការិយាល័យ | សមាជិក |
| ១១- លោក **ពិត គឹមសុខ** | ប្រធានការិយាល័យ | សមាជិក |
| ១២- លោក **ហួន ច័ន្ទឌី** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | សមាជិក។ |

ក្រុមការងារទាំង៤ ខាងលើមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- អនុវត្តគោលការណ៍ណែនាំ ផែនការសកម្មភាព និងសេចក្តីសម្រេចនានា ដែលបានដាក់ចេញ KR

ដោយ **គ.យ.ក.ស.**

- សម្របសម្រួល និងចុះបំពេញការងារនៅតាមសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ដើម្បីពិនិត្យ ប្រមូលទិន្នន័យ និងព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងចំណាត់ការសំណុំរឿងរបស់សាលាដំបូងរាជធានី ខេត្ត
- កំណត់អាទិភាពនៃការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត
- តាមដាន ជំរុញ និងដោះស្រាយនូវបញ្ហាប្រឈមជាក់ស្តែងពាក់ព័ន្ធនឹងការអនុវត្តយុទ្ធនាការនៅតាមសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ដែលស្ថិតក្នុងតំបន់ទទួលខុសត្រូវរបស់ខ្លួន
- ជំរុញការអនុវត្តយុទ្ធនាការឱ្យបានម៉ឺងម៉ាត់ និងឱ្យបានត្រឹមត្រូវតាមច្បាប់
- ចាត់វិធានការទប់ស្កាត់ភាពមិនប្រក្រតីនានា ដែលអាចកើតមានក្នុងពេលយុទ្ធនាការ ព្រមទាំងកសាងសំណុំឯកសារនៃភាពមិនប្រក្រតីនានា រាយការណ៍ជូន **គ.យ.ក.ស.**
- អនុវត្តការកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **គ.យ.ក.ស.**។

**ប្រការ ៣.-**

**គ.យ.ក.ស.** និងក្រុមការងារទាំង៤ខាងលើ មានលេខាធិការដ្ឋានមួយជាសេនាធិការលើការងារបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **នាក់ សើគីរីន** | អនុរដ្ឋលេខាធិការ | អនុប្រធានប្រចាំការ |
| ៣- លោកជំទាវ **ខៀវ សុផានី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម **សន សោភ័ណ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥- ឯកឧត្តម **កើត សេកាណូ** | អគ្គលេខាធិការ | សមាជិក |
| ៦- ឯកឧត្តម **ផូច សំភី** | អគ្គនាយក | សមាជិក |
| ៧- លោកជំទាវ **ប៉ែន សុមេធា** | អគ្គនាយក | សមាជិក |
| ៨- ឯកឧត្តម **យ៉ម ផារ៉ូត** | នាយករងខុទ្ទកាល័យ | សមាជិក |
| ៩- លោកជំទាវ **ម៉ៅ ភិរុណ** | អគ្គនាយករង | សមាជិក |
| ១០- លោកស្រី **ជា ករុណា** | អគ្គនាយករង | សមាជិក |
| ១១- លោក **ណុប វណ្ណៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២- លោក **សេខ សត្យា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣- លោក **ព្រឹក វឌ្ឍបណ្ឌុល** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៤- លោកស្រី **ឌី ម៉ូឡានី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៥- កញ្ញា **សែម សេខវេថៃ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៦- លោក **ផាន់ វណ្ណារ័ត្ន** | ព្រះរាជអាជ្ញា | សមាជិក |
| ១៧- លោកស្រី **សុខ វិសាល** | ព្រះរាជអាជ្ញា | សមាជិក |
| ១៨- កញ្ញា **គា ម៉ីម៉ី** | អនុប្រធាននាយកដ្ឋាន | សមាជិក KR |

| | | |
|---|---|---|
| ១៩- លោក **តាំង សុផា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២០- លោកស្រី **សុតិន វិសាល** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២១- លោក **ចេង សុខមាន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២២- កញ្ញា **អ៊ឹង លាងជូ** | ប្រធានការិយាល័យ | សមាជិក |
| ២៣- លោកស្រី **ចត ចាន់ណា** | ប្រធានការិយាល័យ | សមាជិក |
| ២៤- លោកស្រី **ចិន មុនី** | ប្រធានការិយាល័យ | សមាជិក |
| ២៥- លោកស្រី **ថេត នារ័ត្ន** | អនុប្រធានការិយាល័យ | សមាជិក |
| ២៦- លោក **ភាវអុន សុបញ្ញារិទ្ធ** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | សមាជិក។ |

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងវិធានការ គោលការណ៍ណែនាំ ផែនការសកម្មភាព និងឯកសារចាំបាច់នានា ដើម្បីអនុវត្តយុទ្ធនាការដាក់ជូន **គ.យ.ភ.ស.** ដើម្បីពិនិត្យ និងសម្រេច
- ជាសេនាធិការផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុឱ្យ **គ.យ.ភ.ស.** និងក្រុមការងារទាំង៤ ដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ
- សហការជាមួយក្រុមការងារទាំង៤ ដូចមានចែងក្នុងប្រការ២ ដើម្បីប្រមូល ចងក្រង និងសិក្សាលើទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងចំណាត់ការសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត
- រៀបចំ និងលើកសំណើគម្រោងថវិកាសម្រាប់អនុវត្តយុទ្ធនាការជូនប្រធាន **គ.យ.ភ.ស.** ពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍បូកសរុបដើម្បីដាក់ជូនប្រធាន **គ.យ.ភ.ស.** ពិនិត្យ និងសម្រេច
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធាន **គ.យ.ភ.ស.** ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការក្រសួង គ្រប់អគ្គនាយក អគ្គាធិការ និងគ្រប់ប្រធានអង្គភាពចំណុះក្រសួងយុត្តិធម៌ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ KR

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

កន្លែងទទួល ៖
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ដូចប្រការ៤
  "ដើម្បីជ្រាប និងអនុវត្ត"
  ឯកសារ-កាលប្បវត្តិ